# ប្រ ក ា ស

## ស្តីពី

## ការកំណត់សោហ៊ុយអាជ្ញាប័ណ្ណរបស់ធនាគារពាណិជ្ជ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/ ២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/ ១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០២/ ០៣៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាថ្មីម្តងទៀត
- យោងតាមសំណើរបស់អគ្គនាយកដ្ឋាន

## សំ រេ ច

**ប្រការ ១ .-**

កំណត់សោហ៊ុយអាជ្ញាប័ណ្ណសំរាប់ប្រកបមុខរបររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តាមប្រការជាបន្តបន្ទាប់ដូចខាងក្រោម ។

**ប្រការ ២ ..**

ធនាគារពាណិជ្ជត្រូវបង់សោហ៊ុយអាជ្ញាប័ណ្ណប្រចាំឆ្នាំ នៅធនាគារជាតិនៃកម្ពុជា ដូចខាងក្រោម ÷

១- ទីស្នាក់ការកណ្តាល ÷ ចំនួន ចិតសិបលានរៀល

២- សាខាទី ១០ ចុះក្រោម ÷ ចំនួន ហាសិបប្រាំមួយលានរៀល ក្នុងសាខានិមួយៗ ។

ចាប់ពីសាខាទី ១១ ឡើងទៅ ត្រូវបង់សោហ៊ុយអាជ្ញាប័ណ្ណចំនួនម្ភៃលានរៀល ។

**ប្រការ ៣ ..**

ធនាគារឯកទេសត្រូវបង់សោហ៊ុយអាជ្ញាប័ណ្ណប្រចាំឆ្នាំ នៅធនាគារជាតិនៃកម្ពុជា ដូចខាងក្រោម ÷

១- ទីស្នាក់ការកណ្តាល ÷ ដប់លានរៀល

២- សាខាទី ១០ ចុះ ÷ ប្រាំបីលានរៀល ។ សាខាទី១១ ឡើង ÷ ប្រាំលានរៀល ។

**ប្រការ ៤ ..**

គ្រឹះស្ថានហិរញ្ញវត្ថុត្រូវបង់សោហ៊ុយ ដូចខាងក្រោម ÷

១- ទីស្នាក់ការកណ្តាល ÷ មួយលានរៀល

**ប្រការ ៥ ..**

ការិយាល័យតំណាងរបស់ធនាគារបរទេសនៅកម្ពុជា ត្រូវបង់សោហ៊ុយអាជ្ញាប័ណ្ណ ចំនួនចិតសិបលានរៀល ។

**ប្រការ ៦ ..**

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលបើកទីស្នាក់ការកណ្តាលឬសាខានៅក្នុងឆ្នាំ ត្រូវបង់សោហ៊ុយអាជ្ញាប័ណ្ណ ដូចខាងក្រោម ÷

- ទីស្នាក់ការឬសាខាដែលបានបើក ÷ ក្នុងត្រីមាសទីមួយ ត្រូវបង់ពេញមួយឆ្នាំ
- ក្នុងត្រីមាសទីពីរ ត្រូវបង់បីត្រីមាស
- ក្នុងត្រីមាសទីបី ត្រូវបង់ពីរត្រីមាស
- ក្នុងត្រីមាសទីបួន ត្រូវបង់មួយត្រីមាស ។

**ប្រការ ៧ .-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៨ .-**

ប្រកាសទាំងឡាយពីមុនដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៩ .-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ខែមិនា ឆ្នាំ២០០៤

**ទេសាភិបាល**

**<u>កន្លែងទទួល</u>**

- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**<u>ចម្លងជូន</u>**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាពត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះក្នុងរាជកិច្ច"